**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)**
**Cambodian Water Supply Association (C.W.A)**

# កំណត់ហេតុ
# កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តកំពង់ចាម

## ១. សេចក្តីផ្តើម

ថ្ងៃសុក្រ ១២រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៥ ក្រោមកិច្ចសហការរវាង ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក្រសួង ឧ.វ.ប.ន.) រដ្ឋបាលខេត្តកំពង់ចាម និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានរៀបចំកិច្ចប្រជុំថ្នាក់តំបន់នៅសណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម សម្រាប់សមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនដែលអញ្ជើញមកពីខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ រតនគិរី មណ្ឌលគិរី ព្រៃវែង និងខេត្តស្វាយរៀង។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ ក្រសួង ឧ.វ.ប.ន. **ឯកឧត្តម ឡោ ចាន់លី** អភិបាលរង នៃគណៈអភិបាល ខេត្តកំពង់ចាម និង **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម។

## ២. គោលបំណងនៃកិច្ចប្រជុំថ្នាក់តំបន់

កិច្ចប្រជុំថ្នាក់តំបន់នេះមានគោលដៅ«**ធ្វើការរួមគ្នាដើម្បីជំរុញសេវាកម្មផ្គត់ផ្គង់ទឹកស្អាតឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០៣០**» និងមានគោលបំណងជាក់លាក់ចំនួនបីដូចខាងក្រោម៖

១. ស្តាប់សំឡេងរបស់សមាជិក និងស្វែងរកដំណោះស្រាយជូនសមាជិក
២. បង្កើនទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ និងមន្ទីរពាក់ព័ន្ធ សមាជិកសមាគម និងដៃគូអភិវឌ្ឍន៍នានា
៣. ធ្វើបច្ចុប្បន្នភាពអំពីសមាគម ច្បាប់គតិយុត្តនានាទាក់ទងទៅនឹងវិស័យទឹកស្អាត និងការចែករំលែកចំណេះដឹង បទពិសោធន៍ ព័ត៌មាន និងបច្ចេកវិទ្យាថ្មីៗ។

## ៣. សកម្មភាព និងលទ្ធផលនៃកិច្ចប្រជុំថ្នាក់តំបន់

### ៣.១. កិច្ចស្វាគមន៍ និងសុន្ទរកថាបើកកិច្ចប្រជុំ

#### ក. មតិស្វាគមន៍

**លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម បានស្វាគមន៍ និងថ្លែងអំណរគុណ **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួង ឧ.វ.ប.ន. និង **ឯកឧត្តម ឡោ ចាន់លី** អភិបាលរង នៃគណៈអភិបាលខេត្តកំពង់ចាម ដែលបានផ្តល់ការគាំទ្រ និងកិច្ចសហការរៀបចំកិច្ចប្រជុំនេះបានយ៉ាងល្អ និងសូមអរគុណចំពោះ ឯកឧត្តមអភិបាលរង លោក លោកស្រី ជាប្រធាន ឬតំណាង មន្ទីរពាក់ព័ន្ធទាំងអស់ដែលបានចំណាយពេលវេលាដ៏មមាញឹកអញ្ជើញចូលរួមកិច្ចប្រជុំនេះ។ **លោក ឡេង ខៀវ** បានបញ្ជាក់ជូនថា សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា គឺជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃ មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ និងមិនធ្វើនយោបាយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។ ទស្សនវិស័យសមាគមគឺ« *ចង់ឃើញប្រជាពលរដ្ឋកម្ពុជានៅគ្រប់*

*តំបន់ក្នុងព្រះរាជាណាចក្រកម្ពុជា ទទួលបានសេវាទឹកស្អាត និងអនាម័យ ដែលមានគុណភាពស្របតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ»*។ ទស្សនវិស័យនេះស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានកំណត់ថា **«ត្រឹមឆ្នាំ២០៣០ សម្រេចបាននូវទឹកបរិភោគប្រកបដោយសុវត្ថិភាព និងថ្លៃសមរម្យសម្រាប់មនុស្សគ្រប់គ្នា»**។

## ខ. ចំណាប់អារម្មណ៍របស់ **ឯកឧត្តម ឡោ ចាន់លី** អភិបាលរង នៃគណៈអភិបាលខេត្តកំពង់ចាម

**ឯកឧត្តម ឡោ ចាន់លី** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានគណៈអធិបតី ភ្ញៀវកិត្តិយសទាំងអស់ដែលមានវត្តមានក្នុងអង្គពិធី និងបានសម្តែងនូវក្តីសោមនស្សរីករាយដែលបានចូលរួមក្នុងកម្មវិធីបើក **«កិច្ចប្រជុំថ្នាក់តំបន់»** របស់សមាគមនៅលើទឹកដីខេត្តកំពង់ចាម។ កិច្ចប្រជុំថ្នាក់តំបន់នេះពិតជាការរៀបចំដ៏ល្អមួយដែលមានការអញ្ជើញចូលរួមពីក្រសួងឧ.វ.ប.ន. ដែលជាក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អាជ្ញាធរថ្នាក់ក្រោមជាតិ និងមន្ទីរពាក់ព័ន្ធនានាលើវិស័យផ្គត់ផ្គង់ទឹកស្អាត មកជួបជុំគ្នាដើម្បីចែករំលែកនូវចំណេះដឹង បទពិសោធន៍ ពិភាក្សាគ្នារកដំណោះស្រាយលើបញ្ហាប្រឈមនានាក្នុងការផ្គត់ផ្គង់ទឹកស្អាត។ **ឯកឧត្តម** បានសំណូមពរដល់ប្រតិបត្តិករ មន្ទីរពាក់ព័ន្ធទាំងអស់ សូមលើកឡើងនូវបញ្ហាពិត និងផ្តល់ជូននូវដំណោះស្រាយដែលមានប្រសិទ្ធភាព។ **ឯកឧត្តម**បានផ្តល់នូវអនុសាសន៍មួយចំនួនដូចជាៈ ប្រតិបត្តិករត្រូវវាយបណ្តាញទុយោឱ្យបានពេញតំបន់សេវារបស់ខ្លួន ត្រូវមានប្លង់មេនៃប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត ធ្វើការវិភាគទឹកជាប្រចាំ ធ្វើរបាយការណ៍ជូនមន្ទីរ និងក្រសួងឱ្យបានទៀងទាត់ រៀបចំអាងប្រព្រឹត្តកម្មឱ្យមានអនាម័យខ្ពស់ និងអនុវត្តថ្លៃលក់ទឹកតាមការកំណត់របស់ក្រសួង រៀបចំឱ្យមានផែនការប្រតិបត្តិការ និងផែនការវិនិយោគ រយៈពេលខ្លី វែង និងមធ្យម។

## គ. សុន្ទរកថាបើកកិច្ចប្រជុំ

**ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការបានថ្លែងអំណរគុណចំពោះរដ្ឋបាលខេត្តកំពង់ចាម និងអភិបាលរងខេត្តទាំង៥ មន្ទីរពាក់ព័ន្ធនានា ជុំវិញខេត្ត រដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធមកពីខេត្តក្នុងតំបន់ ដៃគូអភិវឌ្ឍន៍ អង្គការ Water.org លោក លោកស្រី ផ្នែកឯកជន និងសមាជិកសមាគម និងអង្គពិធីទាំងមូល។ **ឯកឧត្តម** បានលើកឡើងពីយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា បានកំណត់វិស័យអាទិភាពគន្លឹះចំនួន៥ គឺ ***«មនុស្ស ផ្លូវ ទឹក ភ្លើង និង បច្ចេកវិទ្យា»*** ដែលក្នុងនោះ ***«ទឹក»*** គឺត្រូវបានរំកិលមកជាអាទិភាពលំដាប់ទី៣ ដោយផ្តោតលើរបៀបវារៈ ***«ធានាប្រសិទ្ធភាព សមិទ្ធកម្ម»*** និងអភិក្រម ***«ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ»***។ វិស័យទឹកស្អាតពាក់ព័ន្ធជាមួយតួអង្គនានាក្នុងសង្គមហើយ ***«ទឹកស្អាតសម្រាប់ទាំងអស់គ្នា»*** ដូចប្រសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងកាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១ ក្នុងនាមនាយករដ្ឋមន្ត្រីនៃកម្ពុជា អាណត្តិទី៦ ដែលបានប្រកាសឱ្យប្រើពាក្យស្លោកនេះ។

ជាមួយគ្នានេះ **ឯកឧត្តម** បានវាយតម្លៃខ្ពស់ចំពោះប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ដែលបានចូលរួមបំពេញកិច្ចការផ្តល់សេវាទឹកស្អាតជូនប្រជាពលរដ្ឋប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ សូមចងចាំថា ***«ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតជាសមត្ថកិច្ចគ្រប់គ្រង និងការទទួលខុសត្រូវដោយផ្ទាល់របស់រដ្ឋ។*** **ឯកឧត្តម** ក៏បានគូសបញ្ជាក់ថា ជាការចាំបាច់ ក្រសួងស្នើជំរុញ និងបន្តផ្តល់ការគាំទ្រប្រកបដោយបុរេសកម្ម និងកិច្ចសហការជិតស្និទ្ធពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ អង្គការ សមាគម និងផ្នែកឯកជន។ ជាមួយគ្នានេះ សូមវាយតម្លៃខ្ពស់ចំពោះប្រតិបត្តិករទឹកស្អាតឯកជន ដែលបានចូលរួមបំពេញកិច្ចការផ្តល់សេវាទឹកស្អាតជូនប្រជាពលរដ្ឋប្រកបដោយស្មារតីទទួលខុសត្រូវ។ សូមចងចាំថា «ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ជាសមត្ថកិច្ចគ្រប់គ្រង និងការទទួលខុសត្រូវដោយផ្ទាល់របស់រដ្ឋ។ រដ្ឋអាចផ្តល់សិទ្ធិជូនវិស័យឯកជនដើម្បីផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ និងផ្នែកផលិតកម្ម សេវាកម្ម ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន» (មាត្រា៤ នៃច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត)។ ហេតុដូច្នេះ ផ្នែកឯកជនរបស់យើងត្រូវមានមោទនភាពចំពោះអ្វីដែលខ្លួនយើងទទួលបានការជឿទុកចិត្តពីរដ្ឋ ទទួលបានការធ្វើប្រតិភូកម្មពីរដ្ឋ ឱ្យខ្លួនយើងដើរតួជំនួសរដ្ឋ ក្នុងនាមរដ្ឋ ធ្វើជាអ្នកផ្តល់សេវាសាធារណៈលើផ្នែកទឹកស្អាតនេះ។ ម្លោះហើយត្រូវខិតខំលើកកម្ពស់ស្មារតីទទួលខុសត្រូវបន្ថែមទៀត ហើយផ្សារ

ភ្ជាប់ជិតស្និទ្ធជាមួយអតិថិជនដែលជាអ្នកទទួលសេវាពីយើង។ រីឯផ្នែករដ្ឋក៏នឹងបន្តជួយគាំទ្រឱ្យពេញទំហឹងដល់ប្រតិបត្តិករយើងវិញដែរ។ **ឯកឧត្តម** បានស្នើឱ្យប្រតិបត្តិករមានផែនទីបណ្ដាញ ព្រោះអាចជួយកាត់បន្ថយការខូចខាតនៅពេលមានការស្ដាបនា និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានា។

### ឃ. បទបង្ហាញ អំពីគោលបំណងនៃកិច្ចប្រជុំ និងបច្ចុប្បន្នភាពអំពីសមាគម

**លោក លឹម មិញ** នាយកប្រតិបត្តិសមាគម បានធ្វើបទបង្ហាញពីគោលបំណងនៃកិច្ចប្រជុំ និងបច្ចុប្បន្នភាពអំពីសមាគម និងបញ្ហាប្រឈមរបស់សមាជិក។ លោកក៏បានជម្រាបជូនអង្គពិធីអំពីគុណតម្លៃ ផែនការយុទ្ធសាស្ត្ររបស់សមាគម ឆ្នាំ២០២៥-២០៣០ ចំនួនសមាជិក និងការបង់វិភាគទានសមាជិកភាព និងបានថ្លែងអំណរគុណចំពោះសមាជិកដែលបានបង់ប្រាក់សមាជិកភាពទៀងទាត់ និងសំណូមពរដល់សមាជិកដែលមិនទាន់បានបង់ សូមចាប់ផ្ដើមបង់សមាជិកភាពមកសមាគម។

## ៣.២. បច្ចុប្បន្នភាពការផ្គត់ផ្គង់ទឹកស្អាត

មន្ទីរ ឧ.រ.ប.ន. ខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ រតនគិរី មណ្ឌលគិរី ព្រៃវែង និងខេត្តស្វាយរៀង បានធ្វើបទបង្ហាញជូនអង្គពិធីនូវបច្ចុប្បន្នភាពនៃការផ្គត់ផ្គង់ទឹកស្អាត បញ្ហាប្រឈម និងដំណោះស្រាយ តាមខេត្តរបស់ខ្លួន។

*តារាង១- ស្ថានភាពនៃសេវាផ្គត់ផ្គង់ទឹកស្អាត*

| | |
|---|---|
| **ខេត្តកំពង់ចាម** | ខេត្តកំពង់ចាមមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសរុបចំនួន ៥៦ស្ថានីយ ក្នុងនោះ ៥៥ជាប្រតិបត្តិករឯកជន និង១ជារដ្ឋាករទឹកកំពង់ចាម។<br>- ចំនួនប្រតិបត្តិករឯកជនដែលទទួលបានប្រកាសអនុញ្ញាតផ្គត់ផ្គង់ទឹកស្អាតរយៈពេល២០ឆ្នាំ មានចំនួន ៤៧ស្ថានីយ<br>- ៤ប្រតិបត្តិករមួយចំនួនទៀតស្ថិតក្នុងដំណាក់កាលនៃការស្នើសុំប្រកាសអនុញ្ញាត<br>- ១ស្ថានីយកំពុងជំរុញឱ្យដាក់ពាក្យស្នើសុំប្រកាស<br>- ៣ស្ថានីយជាទឹកលក្ខណៈសមាគមន៍មានច្បាប់អនុញ្ញាតពីរដ្ឋបាលខេត្ត។<br>ក្នុងនោះ ៥៦ស្ថានីយកំពុងដំណើរការផ្គត់ផ្គង់ទឹកស្អាត។ |
| **ខេត្តត្បូងឃ្មុំ** | ខេត្តត្បូងឃ្មុំមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសរុបចំនួន ២៤ស្ថានីយ ក្នុងនោះ៖<br>- ១ស្ថានីយជារដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ<br>- ១ស្ថានីយជាក្រុមហ៊ុនជាប់កិច្ចសន្យាជាមួយក្រសួង(យុនអភិវឌ្ឍន៍) និង<br>- ២២ស្ថានីយជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។<br>ក្នុងនោះ ១៩ស្ថានីយកំពុងដំណើរការផ្គត់ផ្គង់ ក្នុងនោះ៣ស្ថានីយទិញទឹកដុំសម្រាប់ផ្គត់ផ្គង់ ហើយ ៣ស្ថានីយកំពុងសាងសង់ និង ២ស្ថានីយកំពុងដាក់ពាក្យសុំសិក្សាសមិទ្ធិលទ្ធភាព។ |
| **ខេត្តព្រៃវែង** | ខេត្តព្រៃវែង មានប្រតិបត្តិករសរុបចំនួន ៤០ស្ថានីយ ក្នុងនោះ៖<br>- ៣ស្ថានីយមានទីតាំងនៅខេត្តកណ្ដាល<br>- ៣៥ស្ថានីយទទួលបានប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មទឹកស្អាត<br>- ១ស្ថានីយបានដាក់ពាក្យស្នើសុំប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្ម និង<br>- ១ស្ថានីយមិនទាន់បានដាក់ពាក្យស្នើសុំសិក្សាសមិទ្ធិលភាព។<br>ក្នុងនោះ ៣៣ស្ថានីយកំពុងដំណើរការផ្គត់ផ្គង់ទឹកស្អាត ៤ស្ថានីយកំពុងសាងសង់ស្ថានីយ និង៣ស្ថានីយមិនទាន់បានសាងសង់។ |
| **ខេត្តស្វាយរៀង** | ខេត្តស្វាយរៀង មានប្រតិបត្តិករសរុបចំនួន ១៧ស្ថានីយក្នុងនោះមាន៖ |

ភ្ជាប់ជិតស្និទ្ធជាមួយអតិថិជនដែលជាអ្នកទទួលសេវាពីយើង។ រីឯផ្នែករដ្ឋក៏នឹងបន្តជួយគាំទ្រឱ្យពេញទំហឹងដល់ប្រតិបត្តិករយើងវិញដែរ។ **ឯកឧត្តម** បានស្នើឱ្យប្រតិបត្តិករមានផែនទីបណ្តាញ ព្រោះអាចជួយកាត់បន្ថយការខូចខាតនៅពេលមានការស្ថាបនា និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានា។

### ឃ. បទបង្ហាញ អំពីគោលបំណងនៃកិច្ចប្រជុំ និងបច្ចុប្បន្នភាពអំពីសមាគម

**លោក លឹម មិញ** នាយកប្រតិបត្តិសមាគម បានធ្វើបទបង្ហាញពីគោលបំណងនៃកិច្ចប្រជុំ និងបច្ចុប្បន្នភាពអំពីសមាគម និងបញ្ហាប្រឈមរបស់សមាជិក។ លោកក៏បានជម្រាបជូនអង្គពិធីអំពីគុណតម្លៃ ផែនការយុទ្ធសាស្ត្ររបស់សមាគម ឆ្នាំ២០២៥-២០៣០ ចំនួនសមាជិក និងការបង់វិភាគទានសមាជិកភាព និងបានថ្លែងអំណរគុណចំពោះសមាជិកដែលបានបង់ប្រាក់សមាជិកភាពទៀងទាត់ និងសំណូមពរដល់សមាជិកដែលមិនទាន់បានបង់ សូមចាប់ផ្តើមបង់សមាជិកភាពមកសមាគម។

## ៣.២. បច្ចុប្បន្នភាពការផ្គត់ផ្គង់ទឹកស្អាត

មន្ទីរ ឧ.វ.ប.ន. ខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ រតនគិរី មណ្ឌលគិរី ព្រៃវែង និងខេត្តស្វាយរៀង បានធ្វើបទបង្ហាញជូនអង្គពិធីនូវបច្ចុប្បន្នភាពនៃការផ្គត់ផ្គង់ទឹកស្អាត បញ្ហាប្រឈម និងដំណោះស្រាយ តាមខេត្តរបស់ខ្លួន។

*តារាង១- ខ្សែនភាពនៃសេវាផ្គត់ផ្គង់ទឹកស្អាត*

| | |
|---|---|
| **ខេត្តកំពង់ចាម** | ខេត្តកំពង់ចាមមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសរុបចំនួន ៥៦ស្ថានីយ ក្នុងនោះ ៥៥ជាប្រតិបត្តិករឯកជន និង១ជារដ្ឋាករទឹកកំពង់ចាម។<br>- ចំនួនប្រតិបត្តិករឯកជនដែលទទួលបានប្រកាសអនុញ្ញាតផ្គត់ផ្គង់ទឹកស្អាតរយៈពេល២០ឆ្នាំ មានចំនួន ៤៧ស្ថានីយ<br>- ៤ប្រតិបត្តិករមួយចំនួនទៀតស្ថិតក្នុងដំណាក់កាលនៃការស្នើសុំប្រកាសអនុញ្ញាត<br>- ១ស្ថានីយកំពុងជំរុញឱ្យដាក់ពាក្យស្នើសុំប្រកាស<br>- ៣ស្ថានីយជាទឹកលក្ខណៈសមាគមន៍មានច្បាប់អនុញ្ញាតពីរដ្ឋបាលខេត្ត។<br>ក្នុងនោះ ៥៦ស្ថានីយកំពុងដំណើរការផ្គត់ផ្គង់ទឹកស្អាត។ |
| **ខេត្តត្បូងឃ្មុំ** | ខេត្តត្បូងឃ្មុំមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសរុបចំនួន ២៤ស្ថានីយ ក្នុងនោះ៖<br>- ១ស្ថានីយជារដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ<br>- ១ស្ថានីយជាក្រុមហ៊ុនជាប់កិច្ចសន្យាជាមួយក្រសួង(យុនអភិវឌ្ឍន៍) និង<br>- ២២ស្ថានីយជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។<br>ក្នុងនោះ ១៩ស្ថានីយកំពុងដំណើការផ្គត់ផ្គង់ ក្នុងនោះ៣ស្ថានីយទិញទឹកដុំសម្រាប់ផ្គត់ផ្គង់ ហើយ ៣ស្ថានីយកំពុងសាងសង់ និង ២ស្ថានីយកំពុងដាក់ពាក្យសុំសិក្សាសមិទ្ធិលទ្ធភាព។ |
| **ខេត្តព្រៃវែង** | ខេត្តព្រៃវែង មានប្រតិបត្តិករសរុបចំនួន ៤០ស្ថានីយ ក្នុងនោះ៖<br>- ៣ស្ថានីយមានទីតាំងនៅខេត្តកណ្តាល<br>- ៣៥ស្ថានីយទទួលបានប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មទឹកស្អាត<br>- ១ស្ថានីយបានដាក់ពាក្យស្នើសុំប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្ម និង<br>- ១ស្ថានីយមិនទាន់បានដាក់ពាក្យស្នើសុំសិក្សាសមិទ្ធិលភាព។<br>ក្នុងនោះ ៣៣ស្ថានីយកំពុងដំណើរការផ្គត់ផ្គង់ទឹកស្អាត ៤ស្ថានីយកំពុងសាងសង់ស្ថានីយ និង៣ស្ថានីយមិនទាន់បានសាងសង់។ |
| **ខេត្តស្វាយរៀង** | ខេត្តស្វាយរៀង មានប្រតិបត្តិករសរុបចំនួន ១៧ស្ថានីយក្នុងនោះមាន៖ |

| | | | |
|---|---|---|---|
| ៣ | ការសហការរវាងអាជ្ញាធរ ក្រុមហ៊ុនសាងសង់ផ្លូវថ្នល់ និងប្រតិបត្តិករ | - សូមប្រតិបត្តិករចូលរួមសហការគ្នាឱ្យបានប្រសើរ<br>- សមត្ថកិច្ចទទួលបន្ទុកវិស័យទឹកស្អាត ត្រូវបន្តកិច្ចសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា<br>- សមត្ថកិច្ចទទួលបន្ទុកវិស័យទឹកស្អាត បង្កលក្ខណៈងាយស្រួលអំណោយផលគ្រប់បែបយ៉ាង ដល់ការលូតលាស់ នៃ វិស័យផ្គត់ផ្គង់ទឹកស្អាត។<br>- ភាគីពាក់ព័ន្ធសហការផ្តល់ព័ត៌មានជូនគ្នា រួមទាំងគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ | មណ្ឌលគិរី ព្រៃវែង ស្វាយរៀង |
| ៤ | ការដាក់បណ្តាញយឺតយ៉ាវ | - ត្រូវខិតខំពង្រីកបណ្តាញចែកចាយទៅតាមផែនការឱ្យបានទាន់ពេលវេលា និងមិនរំលងតំបន់សេវាដែលគ្មានសក្តានុពល<br>- ត្រូវកំណត់ផែនការប្រតិបត្តិការផ្គត់ផ្គង់ទឹកស្អាតឱ្យបានច្បាស់លាស់។ | ព្រៃវែង |
| ៥ | ចំណេះដឹងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាននៅមានកម្រិត | - បង្កើនការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាជនរដ្ឋអំពីទឹកស្អាត | កំពង់ចាម ត្បូងឃ្មុំ មណ្ឌលគិរី រតនគិរី |
| ៦ | ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋនៅមានកំរិត | - បង្កើនផ្សព្វផ្សាយអំពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាតជូនអាជ្ញាធរ និងប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ដើម្បីឱ្យគាត់យល់ហើយប្រើប្រាស់ទឹកស្អាតបានច្រើន។ | ត្បូងឃ្មុំ |
| ៧ | ខ្វះទុនវិនិយោគ | - ស្ថាប័នផ្តល់កម្ចីសម្រួលដំណើរការ និងឯកសារកម្ចី ដើម្បីទទួលបានកម្ចីលឿន<br>- សមាគមគួរមានទុនជួយដល់ប្រតិបត្តិករ<br>- រៀបចំត្រៀមឯកសារពាក់ព័ន្ធ និងពង្រឹងការអនុវត្តតាមបច្ចេកទេសអោយបានសមស្រប។ | ត្បូងឃ្មុំ ក្រចេះ ស្វាយរៀង រតនគិរី |
| ៨ | តំបន់សេវានៅឆ្ងាយត្រូវចំណាយខ្ពស់ | - ក្រសួងពិនិត្យសម្រួលនីតិវិធី និងសម្រួលបទបញ្ញត្តិទូទៅមួយចំនួនដល់ការវិនិយោគរបស់ប្រតិបត្តិករ ពិសេសប្រតិបត្តិករតូចៗ | រតនគិរី មណ្ឌលគិរី |
| ៩ | ចំណេះដឹងបច្ចេកទេសរបស់ប្រតិបត្តិករ ក្នុងការលាយសារធាតុគីមី (បច្ចេកទេស និងឧបករណ៍) | - គួរមានវគ្គបណ្តាលដល់ប្រតិបត្តិករ<br>- ប្រតិបត្តិករចូលរួមវគ្គបណ្តុះបណ្តាលឱ្យបានច្រើន<br>- ប្រតិបត្តិករត្រូវរៀបចំឧបករណ៍តេស្តបឋម(៥ប៉ារ៉ាម៉ែត្រ) និងបន្ទប់ពិសោធន៍ឱ្យបានត្រឹមត្រូវ។ | រតនគិរី ព្រៃវែង |
| ១០ | កង្វះខាតធនធានមនុស្សដែលមានជំនាញ លើការ | - ប្រតិបត្តិករចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រប់ជំនាញ ពាក់ព័ន្ធនឹងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដើម្បីបង្កើនសមត្ថភាពធនធានមនុស្ស ដែលត្រូវយកចិត្តទុកដាក់ជាចាំបាច់។ | ស្វាយរៀង កំពង់ចាម |

| | | | |
|---|---|---|---|
| | គ្រប់គ្រងអាជីវកម្ម និងបច្ចេកទេស | ប្រតិបត្តិករត្រូវរៀបចំការគ្រប់គ្រងទិន្នន័យអាជីវកម្មរបស់ខ្លួនឱ្យបានច្បាស់លាស់ | |
| ១១ | ប្រតិបត្តិករមិនបានផ្តល់របាយការណ៍ និងព័ត៌មានមកអាជ្ញាធរ មន្ទីរ និងក្រសួងឱ្យបានពេញលេញ និងទាន់ពេលវេលា | - ប្រតិបត្តិករត្រូវផ្តល់ការសហការជាមួយក្រសួង និងមន្ទីរ រួមទាំងអាជ្ញាធរមូលដ្ឋានឱ្យបានពេញលេញ | កំពង់ចាម ព្រៃវែង |
| ១២ | ប្រតិបត្តិករពុំបានអនុវត្តតាមលក្ខខណ្ឌប្រកាសអនុញ្ញាត | - ប្រតិបត្តិករត្រូវខិតខំពង្រីកបណ្តាញចែកចាយទៅតាមផែនការឱ្យបានទាន់ពេលវេលា និងមិនរំលងតំបន់សេវាដែលគ្មានសក្តានុពល | កំពង់ចាម ព្រៃវែង |
| ១៣ | មិនយកចិត្តទុកដាក់លើប្រព័ន្ធប្រព្រឹត្តកម្ម អនាម័យ និងប្រព័ន្ធការសុវត្ថិភាព | - ត្រូវយកចិត្តទុកដាក់ទៅលើប្រព័ន្ធអាងប្រព្រឹត្តកម្ម ប្រព័ន្ធអនាម័យជុំវិញស្ថានីយ ជាពិសេសក្បែរអាងប្រព្រឹត្តកម្ម និងស្ថានីយទឹកឆៅ និងការដាក់ដំបូលអាងប្រព្រឹត្តកម្ម បង្កាន់ដៃការរៀបចំប្រព័ន្ធសុវត្ថិភាពភ្លើងឱ្យបានត្រឹមត្រូវ។ | ព្រៃវែង |
| ១៤ | ប្រតិបត្តិករភាគច្រើនមិនបានរៀបចំកិច្ចប្រជុំវេទិកាសាធារណៈយ៉ាងតិច ១ឆ្នាំម្តង តាមប្រកាសអនុញ្ញាត | - តម្រូវឱ្យប្រតិបត្តិកររៀបចំកិច្ចប្រជុំវេទិកាសាធារណៈយ៉ាងតិច ១ឆ្នាំម្តង តាមប្រកាសអនុញ្ញាត | ព្រៃវែង |

### ៣.៣. បទបង្ហាញរបស់ធនាគារសហគ្រាសធុនតូច និងមធ្យម (SME Bank)

ធនាគារ SME អាចផ្តល់ទំហំឥណទានរហូតដល់ ៣លានដុល្លារ សម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត រយៈពេល ៧ឆ្នាំ សម្រាប់ទុនបង្វិល និងដល់រយៈពេល ១០ឆ្នាំ សម្រាប់ទុនវិនិយោគ។ សម្រាប់គម្រោងហិរញ្ញប្បទានមានទ្រព្យធានា៖ ទទួលបានឥណទានរហូតដល់ ៨០% សម្រាប់ប្លង់រឹង ឬ ៧០% សម្រាប់ប្លង់ទន់។ សម្រាប់គម្រោងហិរញ្ញប្បទានមិនមានទ្រព្យធានា៖ អាចទទួលបានឥណទានមិនតម្រូវឱ្យមានទ្រព្យធានារហូតដល់ ៥០០.០០០ ដុល្លារអាមេរិក។ សម្រាប់សោហ៊ុយរៀបចំឥណទាន ០,៥% យកតែម្តងគត់។ ប្រតិបត្តិករជាសមាជិកសមាគមនឹងទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំដូចខាងក្រោម៖

| បរិយាយ | អត្រាការប្រាក់ប្រចាំឆ្នាំសម្រាប់ប្រតិបត្តិករទឹកស្អាត |
|---|---|
| **ឥណទានជាប្រាក់រៀល** | |
| ម្ចាស់សហគ្រាសជាស្ត្រី | 5.00% |
| ម្ចាស់សហគ្រាសជាបុរស | 5.25% |

| ឥណទានជាប្រាក់ដុល្លារអាមេរិក | |
|---|---|
| ម្ចាស់សហគ្រាសជាស្ត្រី | 5.25% |
| ម្ចាស់សហគ្រាសជាបុរស | 5.50% |

ប្រតិបត្តិករដែលជាសមាជិកសមាគមនឹងទទួលបានការបញ្ចុះការប្រាក់ 0.25% ពីធនាគារ សហគ្រាសធុនតូច និងមធ្យម កម្ពុជា តាមរយៈអនុស្សរណៈយោគយល់គ្នារវាង ធនាគារ SME និងសមាគម CWA។

## ៣.៤. ការបង្ហាញអំពីបញ្ហារបស់ប្រតិបត្តិករ តាមខេត្តនីមួយៗ

**លោកស្រី ស៊ីម សៀមនី** អនុប្រធានក្រុមប្រឹក្សាភិបាលសមាគម បានបង្ហាញនូវបញ្ហាប្រឈមរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតតាមខេត្តនីមួយៗ។

*តារាង៣- បញ្ហាប្រឈមចម្បងៗ*

| ខេត្ត | បញ្ហាប្រឈមចម្បងៗ |
|---|---|
| **ខេត្តកំពង់ចាម** | ❑ ការខូចខាតបណ្តាញបំពង់ទឹកស្អាត ដោយសារការអភិវឌ្ឍផ្លូវ និងដោយសារប្រជាពលរដ្ឋ<br>❑ មិនមានការជូនដំណឹងជាមុនពីការធ្វើផ្លូវ និងមិនមានសំណង<br>❑ មិនមានកិច្ចសហការពីក្រុមការងារធ្វើផ្លូវ<br>❑ ការគាំទ្រ និងកិច្ចសហការរវាងអាជ្ញាធរមូលដ្ឋាន ជាមួយប្រតិបត្តិករនៅមានកម្រិត<br>❑ ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅមានកម្រិតពីសារៈប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់<br>❑ ការប្រើប្រាស់ទឹករបស់អតិថិជននៅមានកម្រិត នាំឱ្យមានចំណូលទាប<br>❑ មានការបំពុលប្រភពទឹកពីការប្រើប្រាស់ជី និងថ្នាំគីមី ដើម្បីធ្វើស្រែចំការរបស់ប្រជាពលរដ្ឋ<br>❑ ខ្វះខាតប្រភពទឹកនៅរដូវប្រាំង<br>❑ ទីតាំងភូមិសាស្ត្រនៃរយៈកម្ពស់សណ្ឋានដីមានភាពខុសគ្នាខ្លាំង(ធ្វើឱ្យការចែកចាយទឹកត្រូវចំណាយថាមពលខ្ពស់ ប្រឈមការបាត់បង់ទឹក...)។ |
| **ខេត្តត្បូងឃ្មុំ** | ❑ ខូចខាតបណ្តាញបំពង់ទឹកស្អាតពីការធ្វើផ្លូវ និងប្រជាពលរដ្ឋ<br>❑ ខ្វះខាតប្រភពទឹកនៅរដូវប្រាំង<br>❑ ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅមានកម្រិតស្តីពីសារៈប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់<br>❑ ការភ្ជាប់បណ្តាញបំពង់ទឹកស្អាត និងប្រើប្រាស់ទឹកស្អាតតាមបំពង់ពីប្រជាពលរដ្ឋនៅមានកម្រិត<br>❑ ត្រូវការទុនវិនិយោគខ្ពស់ក្នុងការពង្រីកបណ្តាញបំពង់ទៅតំបន់ដាច់ស្រយាល<br>❑ នៅក្នុងតំបន់សេវាកម្មមានអ្នកលក់ទឹកផៅ<br>❑ ពិបាកក្នុងការជ្រើសរើសបុគ្គលិកជំនាញមកធ្វើការ។ |
| **ខេត្តព្រៃវែង** | ❑ ការខូចខាតបណ្តាញបំពង់ទឹកស្អាតពីការធ្វើផ្លូវ និងពីសកម្មភាពនានារបស់ប្រជាពលរដ្ឋ<br>❑ មិនមានសំណងពីការខូចខាតបំពង់ពីការធ្វើផ្លូវ<br>❑ អត្រាទឹកគ្មានចំណូលខ្ពស់ដែលបណ្តាលមកពី៖ គុណភាពសម្ភារដែលប្រើប្រាស់ បច្ចេកទេសក្នុងការដំឡើងបំពង់ មិនមានបុគ្គលិកជំនាញក្នុងការស្វែងរកទឹកបាត់បង់...<br>❑ ខ្វះខាតប្រភពទឹកនៅតំបន់មួយចំនួននៅរដូវប្រាំង |

da

| ខេត្ត | បញ្ហាប្រឈមចម្បងៗ |
| --- | --- |
| | ❑ ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅមានកម្រិតពីសារៈប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់<br>❑ ការភ្ជាប់ទឹកស្អាតតាមបំពង់របស់ប្រជាពលរដ្ឋនៅមានកម្រិត<br>❑ របាយប្រជាជននៅរាយប៉ាយពិបាកក្នុងការរាយបណ្ដាញបំពង់។ |
| **ខេត្តស្វាយរៀង** | ❑ ការខូចខាតបណ្តាញបំពង់ទឹកស្អាតពីការធ្វើផ្លូវ និងការធ្វើស្រែចំការពីប្រជាពលរដ្ឋ<br>❑ ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅមានកម្រិតស្តីពីសារៈប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់<br>❑ ការបំពុលប្រភពទឹកពីរោងចក្រ<br>❑ ខ្វះខាតប្រភពទឹក (បឹងដូនទយ) និងការប្រើប្រាស់ទឹកក្រោមដីច្រើនពេក<br>❑ ផលរំខានពីប្រតិបត្តិករដែលមិនមានអាជ្ញាបណ្ណ (ទឹកផៅ) ក្នុងតំបន់សេវាកម្ម។ |
| **ខេត្តក្រចេះ** | ❑ ការខូចខាតបណ្តាញបំពង់ទឹកស្អាតពីការធ្វើផ្លូវ និងការធ្វើស្រែចំការពីប្រជាពលរដ្ឋ<br>❑ ត្រូវចំណាយដើម្បីទុនខ្ពស់ក្នុងការពង្រីកបណ្តាញបំពង់បន្ថែម ដោយសារតំបន់នៅដាច់ស្រយាល និងប្រជាជនតិច<br>❑ ខ្វះប្រភពទឹកសម្រាប់យកមកផលិត និងចែកចាយនៅចុងរដូវប្រាំង (ទំនប់ស្វាយជ្រុំ)<br>❑ ការបំពុលប្រភពទឹកពីការប្រើប្រាស់ជី និងថ្នាំធ្វើកសិកម្ម និងចំការ<br>❑ ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅមានកម្រិតស្តីពី សារៈប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់<br>❑ ការយល់ដឹងពីច្បាប់ពន្ធដានៅមានកម្រិត<br>❑ ការភ្ជាប់ទឹកស្អាត និងការប្រើប្រាស់ទឹកស្អាតតាមបំពង់របស់ប្រជាពលរដ្ឋនៅមានកម្រិត (ប្រើប្រាស់ប្រភពទឹកដែលមានស្រាប់)។ |
| **ខេត្តរតនគិរី និងមណ្ឌលគិរី** | ❑ ការខូចខាតបណ្តាញបំពង់ទឹកស្អាតពីការធ្វើផ្លូវ គ្មានសំណង និងមិនមានកិច្ចសហការ<br>❑ អាជ្ញាធរមិនសហការក្នុងការយកប្រភពទឹកមកផលិត ដើម្បីផ្គត់ផ្គង់ទៅអតិថិជន (ទំនប់ទឹកអាងក្រពើ)<br>❑ ខ្វះខាតប្រភពទឹកក្នុងរដូវប្រាំង<br>❑ អាជ្ញាធរ និងប្រជាពលរដ្ឋនៅមានកម្រិតស្តីពីសារៈប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាតតាមបំពង់។ |

## ៣.៥. វេទិកាពិភាក្សាតុមូល

### ក. វេទិកាពិភាក្សាតុមូលលើបញ្ហាប្រឈមទី១

លោក **លឹម មិញ** បានសម្របសម្រួលកិច្ចពិភាក្សាលើប្រធានបទ៖ ១).ការខូចខាតបណ្តាញបំពង់ទឹកស្អាត និង ២). កិច្ចសហការរវាងប្រតិបត្តិករ និងភាគីពាក់ព័ន្ធ។ កិច្ចពិភាក្សានេះអញ្ជើញចូលរួមដោយវាគ្មិនកិត្តិយសមកពីមន្ទីរពាក់ព័ន្ធរួមមាន៖ ១. មន្ទីរ ឧ.រ.ប.ន ខេត្តកំពង់ចាម ២. មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តព្រៃវែង ៣. មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តក្រចេះ និង ៤. មន្ទីរមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។

*តារាង៤- សង្ខេបអំពីកិច្ចពិភាក្សា*

| វាគ្មិន | ដំណោះស្រាយកន្លងមក | អនុសាសន៍ |
| --- | --- | --- |
| មន្ទីរ ឧ.រ.ប.ន . (កំពង់ចាម) | - យើងមានច្បាប់ស្តីពីការគ្រប់គ្រងទីស្អាត ក្រសួងបានផ្សព្វផ្សាយរួចហើយ<br>- ក្រុមហ៊ុនសាងសង់ផ្លូវផ្ទាល់ ត្រូវមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយ (ព័ត៌មានភាគច្រើនទើត្រឹមអាជ្ញាធរមូលដ្ឋាន មិនបានដល់ប្រតិបត្តិករទេ)<br>- រួមសហការគ្នានៅពេលចុះឈូសឆាយ ជូនដំណឹងហើយសហការណ៍គ្នាឱ្យបានជិតស្និត។ | |
| សាធារណការ និងដឹកជញ្ជូន (ក្រចេះ) | - មានគម្រោង២ គឺគម្រោងរបស់រដ្ឋាភិបាល (មិនមានសំណងបានទេ) និងកម្ចីឥណទាន (ជាមួយ ADB និង World Bank អាចមានសំណង)<br>- ប្រតិបត្តិករត្រូវសុំមកមន្ទីរ ដើម្បីសុំការប្រើប្រាស់ដីចំណីផ្លូវ<br>- មន្ទីរក៏មានការសម្របសម្រួលក្នុងករណីផ្ទះប្រជាពលរដ្ឋមិនមានសណ្តាប់ធ្នាប់។ ដូច្នេះប្រតិបត្តិករត្រូវមានលិខិតស្នើសុំ និងកិច្ចសន្យាមួយ ដើម្បីសម្របសម្រួល និងសហការគ្នា។<br>- មានគណៈកម្មាធិការដោះស្រាយបណ្តឹងនៃកាខូចខាត (មានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាធារណការ និងដឹកជញ្ជូន ជាសមាជិក)។<br>- ថ្នាក់ខេត្តមានអនុគណៈកម្មាធិការដោះស្រាយបណ្តឹងនៃកាខូចខាត ។ នៅក្រចេះមិនទាន់បានអនុវត្តនៅឡើយទេ មានតែនៅបន្ទាយមានជ័យ និងសៀមរាប។ | - មន្ទីរស្នើសុំឱ្យប្រតិបត្តិករជូនដំណឹងមកមន្ទីរសាធារណការនិងដឹកជញ្ជូន ដល់ពេលត្រូវដាក់បណ្តាញ។<br>- យើងត្រូវរួមគ្នាដោះស្រាយបញ្ហាប្រឈមរួមគ្នា<br>- ស្នើសុំឱ្យមានសូចនាករណាមួយក្នុងពេលដេញថ្លៃ ដើម្បីឱ្យក្រុមហ៊ុនមៅការចូលរួមដោះស្រាយ។ |
| មន្ទីរអភិវឌ្ឍន៍ជនបទ (ព្រៃវែង) | - ការកប់ទុយោ ត្រូវជូនដំណឹងមកមន្ទីរជំនាញ<br>- ក្រសួងធ្វើផ្លូវមិនមានសំណងទេ ត្រូវតែបរិច្ចាក ព្រោះមិនបានទទួលពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទេ តែបើគម្រោងធំៗខ្លះទើបមាន។ | - គួរកប់ទុយោទឹកស្អាតឱ្យបានជ្រៅទើបល្អ |
| មន្ទីរដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (ស្វាយរៀង ) | - យើងធ្វើការដោយមានការចូលរួមទាំងមន្ទីរពាក់ព័ន្ធ អាជ្ញាធរ និងប្រជាពលរដ្ឋ<br>- បច្ចុប្បន្នគ្រប់ផ្លូវត្រូវបានចុះបញ្ជីដីធ្លីរួចហើយ។ | - សូមឱ្យមានការចូលរួមដោះបញ្ហារួមគ្នាដោយៈ<br>ផ្នែកបច្ចេកទេសៈ ប្រតិបត្តិករមុននឹងដាក់បណ្តាញត្រូវជូនដំណឹងមកមន្ទីរទទួលបន្ទុក និងផ្តល់ព័ត៌មានទៅមន្ទីរពាក់ព័ន្ធ។ ដើម្បីដោះស្រាយត្រូវគិតទាំងលូ ខ្សែកាប និងបណ្តាញទឹកស្អាត ដោយមានផែនទីបណ្តាញច្បាស់លាស់ ចៀសវាងប៉ះពាល់ដល់បណ្តាញ។ |

| វាគ្មិន | ដំណោះស្រាយកន្លងមក | អនុសាសន៍ |
|---|---|---|
| | | ផ្នែករដ្ឋបាលៈ ត្រូវជូនដំណឹងដល់ប្រជាពលរដ្ឋ និងប្រតិបត្តិករឱ្យមានការយល់ដឹងអំពីការប្រើប្រាស់ដីចំណីផ្លូវ។<br>- អាជ្ញាធរមេត្តាជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>- ប្រតិបត្តិករចង់ធ្វើអ្វីមួយត្រូវពិភាក្សាជាមួយមន្ទីរ ឧ.វ.ប.ន.<br>- ប្រតិបត្តិករត្រូវមានប្លង់បណ្តាញច្បាស់លាស់<br>- សូមស្ថាប័នដែលធ្វើផ្លូវត្រូវទុកចំណីផ្លូវឱ្យហើយ<br>- ប្រតិបត្តិករអាចសុំប្លង់ផែនទីផ្លូវពីមន្ទីរសុរិយោដី តាមរយៈមន្ទីរឧ.វ.ប.ន.។ |
| **សមាគម** | - មានលិខិតមួយចេញពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការបញ្ចៀសកម្រិតអតិបរមារពីផលប៉ះពាល់បណ្តាញទឹកស្អាត។ | - ស្នើសុំរាល់ការសិក្សាពង្រីក និងជួសជុលផ្លូវថ្នល់ លូ សូមអញ្ជើញប្រតិបត្តិករចូលរួមប្រជុំ និងសិក្សាអំពីផលប៉ះពាល់ផងដែរ។<br>- ស្នើសុំឱ្យអ្នកម៉ៅការសាងសង់ផ្លូវយោគយល់ដល់ការខូចខាតបណ្តាញទឹកស្អាត<br>- អនុសាសន៍ពីសមាគមៈ ប្រតិបត្តិករ ធ្វើយ៉ាងណាមានផែនទីបណ្តាញ ដាក់ជូនអាជ្ញាធរ និងមន្ទីរពាក់ព័ន្ធទាំងអស់<br>- **ឯកឧត្តម អ៊ុំ សុផា** បានបង្ហាញ និងពន្យល់បន្ថែមអំពីខ្លឹមសារលិខិតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ |
| **សំណួរ ចម្លើយ** | ***សំណួរ១(លោកស៊ីវហួត)៖*** ទៅមន្ទីរដែនដី តើប្លង់បណ្តាញថ្នល់ (កាប លូ បណ្តាញទឹក) អាចយកមកពីស្ថាប័នណា?<br>***ចំម្លើយ៖*** លូ និងចំណីផ្លូវគឺមន្ទីរសាធារណការ ទឹកស្អាតគឺឧស្សាហកម្ម។<br><br>***សំណួរ២៖*** តើដាក់បំពង់ទឹកស្អាតយ៉ាងណាទើបត្រឹមត្រូវ?<br>***ចម្លើយ៖*** បើចង់ដាក់ឱ្យត្រូវតែម្តង លុះត្រាតែចាំធ្វើផ្លូវរួចចាំដាក់។ ការធ្វើផ្លូវមានការប៉ះពាល់ច្រើនណាស់មិន | ***សំណូមពរ (លោក ប៉ោ ពួច)៖*** ក្រសួងមានសមត្ថកិច្ចគួរសហការគ្នាចេញច្បាប់មួយរួមដើម្បីឱ្យអាជីវករទឹកស្អាតអនុវត្តតាម។ សូមជួយអន្តរាគមការស្នើសុំយកបឹងក្រពើជាប្រភពទឹកផង។<br><br>***សំណូមពរពីមណ្ឌលគិរី៖*** ធ្វើយ៉ាងណាជួយសម្រួល ការសងសំណងផង ព្រោះបើម្តងជាពីរដង មានការខាតបង់ច្រើនណាស់។ យើងអាចយកបញ្ហាដាក់លើតុដើម្បីដោះស្រាយរួមគ្នាចំណោញទាំង |

| វាគ្មិន | ដំណោះស្រាយកន្លងមក | អនុសាសន៍ |
|---|---|---|
| | មែនតែបំពង់ទឹកស្អាតនោះទេ ពេលធ្វើផ្លូវយើងអាចដាក់បំពង់លើចិញ្ចើមផ្លូវសិនទៅ។<br>***ចម្លើយ៖*** យើងមានគម្រោងច្រើនតែមិនមានការប៉ះពាល់ដល់បំពង់ទឹកស្អាតនោះទេ។ ជាទូទៅបើគម្រោង ធំៗ យើងពិភាក្សាគ្នាដើម្បីសង តែបើតិចតួចគេ ពិភាក្សាដើម្បីបរិច្ចាគ។<br><br>***សំណួរ (លោកអេងឡាយ)៖*** តើយើងមានយន្តការដូចម្តេចដើម្បីឱ្យប្រជាជនកុំចាក់ដីខ្ពស់ជាងផ្លូវជាតិ (មន្ទីរដែនដី)? ព្រោះតែងតែមានការចាក់ដី ហើយដក់ទឹកលើផ្លូវ អាជ្ញាធរនឹងកាយ នៅពេលកាយនឹងដាច់បំពង់ទឹកស្អាត?<br>***ចម្លើយ៖*** ពេលដាក់បំពង់ត្រូវគោរពតាមច្បាប់រដ្ឋ ម្យ៉ាងទៀតយើងត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន គឺមានតែការចូលរួមទាំងអស់គ្នាទេ ទើបអាចកាត់បន្ថយការខូចខាត។ | ប្រជាពលរដ្ឋ ប្រតិបត្តិករ និងគោលនយោបាយ។<br><br>***អភិបាលរងខេត្តកំពង់ចាម៖*** អនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី មន្ត្រីទាំងអស់សូមចុះទៅជួយប្រជាពលរដ្ឋ កុំចុះទៅចាប់។<br>• សេវាកាតព្វកិច្ចៈ ទឹក ភ្លើង សន្តិសុខ សណ្តាប់ធ្នាប់...<br>• សេវាតម្រូវការៈ អត្តសញ្ញាបណ្ណ សំបុត្រកំណើត សៀវភៅគ្រួសារ...<br>• សេវាសំណូមពរៈ សុំសាងសង់ ធ្វើអាជីវកម្ម...<br>បងប្អូនប្រតិបត្តិករអាចរករដ្ឋបាលស្រុកឱ្យជួយ រួចមកមន្ទីរ និងមកខេត្ត ខ្ញុំនឹងខិតខំជួយសម្របសម្រួលជូនប្រតិបត្តិកររបស់យើងឱ្យបានជាអតិបរិមា។ |
| **សំណូមពរពីប្រតិបត្តិករ** | ***សំណូមពរពីអាជីវករ មកពីខេត្តស្វាយរៀង ស្រុកចន្ទ្រា៖*** ចំពោះខេត្តស្វាយរៀង សូមជួយសម្របសម្រួលការប្រើប្រាស់ប្រភពទឹកក្រោមដី ការបង្ហូរទឹកកខ្វក់ចូលប្រភពទឹកតាមលូ មានអ្នកលក់ទឹកដោយគ្មានអាជ្ញាបណ្ណ សូមមន្ទីរ និងក្រសួងជួយពន្លឿនអាជ្ញាបណ្ណ។ | **ឯកឧត្តម អ៊ុំ សុឋា** បញ្ហានេះយើងនឹងពិភាក្សាដោយឡែក ជាមួយភាគីពាក់ព័ន្ធទាំងអស់ដោយសារមានបញ្ហាទំនាស់ទាក់ទងនឹងតំបន់សេវានៃអាជ្ញាបណ្ណ និងមានកិច្ចប្រជុំនៅក្រសួង ១លើកហើយ។ |

## ខ. វេទិកាពិភាក្សាតុមូលលើបញ្ហាប្រឈមទី២

លោក **លឹម មិញ** បានសម្របសម្រួលកិច្ចពិភាក្សាលើប្រធានបទៈ ការធានាបាននូវនិរន្តរភាពប្រភពទឹកសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត។ កិច្ចពិភាក្សានេះអញ្ជើញចូលរួមដោយវាគ្មិនកិត្តិយសមកពីមន្ទីរពាក់ព័ន្ធរួមមានៈ១. មន្ទីរ ឧ.វ.ប.ន. ខេត្តមណ្ឌលគិរី ២. មន្ទីររ៉ែ និងថាមពល ខេត្តត្បូងឃ្មុំ ៣. មន្ទីរធនធានទឹក និងឧតុនិយម ខេត្តព្រៃវែង និង ៤. តំណាងអគ្គនាយកដ្ឋានទឹកស្អាត ក្រសួងឧ.វ.ប.ន.។

*តារាង៧- សង្ខេបអំពីកិច្ចពិភាក្សា*

| វាគ្មិន | ដំណោះស្រាយកន្លងមក | អនុសាសន៍ |
|---|---|---|
| **មន្ទីរធនធានទឹក និងឧតុនិយម (ព្រៃវែង)** | - អាជីវករខ្លះយកទឹកក្រោមដី ហើយខ្លះយកទឹកលើដី ម្យ៉ាងទៀត គាត់ទំនាក់ទំនងតែជាមួយមន្ទីរ ឧ.វ.ប.ន. ទេ។ | |

| | | |
|---|---|---|
| | - រដ្ឋយកភាគទានសម្រាប់ការថែទាំប្រព័ន្ធធារាសាស្ត្រ ១០ ម៉ឺនរៀលក្នុង១ហិចតា សម្រាប់១រដូវ។ ករណីទឹកនេះ មានតែនៅកន្លែងដែលបានបង្កើតសហគមន៍ប៉ុណ្ណោះ។<br>- មន្ទីរមិនដែលមានទំនាក់ទំនងជាមួយប្រតិបត្តិករដើម្បី ជជែកពិភាក្សាអំពីបរិមាណតម្រូវការទឹកនោះទេ វិភាគទានប្រើប្រាស់ប្រភពទឹកក៏មិនបានយកពី ប្រតិបត្តិករដែរ។<br>- បើវិស័យកសិកម្ម មន្ទីរធនធានទឹកបានយកកម្រៃពី កសិករដែលបានដកទឹកប្រើប្រាស់ពីប្រឡាយរបស់រដ្ឋ ១ម³មិនដល់ ១០០រនោះទេ (១ហិចតាប្រមាណ ១០ ម៉ឺនរៀល/រដូវ) សម្រាប់សហគមន៍។ | |
| **មន្ទីរ ឧ.វ.ប.ន. (មណ្ឌលគិរី)** | - ជាការងាររួមក្នុងខេត្ត សហការគ្នាជាមួយខេត្ត មន្ទីរ ធនធានទឹក និងប្រតិបត្តិករ ធ្វើទំនប់ស្អាក់ទឹកតាមជ្រោះ និងអូរ បើធ្វើមិនបានយើងជីកជាស្រះ តែយើងត្រូវការ ទុនធំ ។ យើងត្រូវធ្វើទំនប់អូរច្បារតាមផ្លូវទៅកោះញែក ការងារទាំងនេះជាកិច្ចសហការគ្នា។<br>- ដើម្បីឱ្យប្រតិបត្តិករមាននិរន្តរភាពប្រភពទឹក មន្ទីរ ឧ.វ.ប.ន. បានសហការជាមួយរដ្ឋបាលខេត្ត មន្ទីរ ធនធានទឹក និងប្រតិបត្តិករ។<br>- នៅខេត្តមណ្ឌលគិរីសំបូរទឹកនៅរដូវវស្សា តែនៅរដូវប្រាំង ខ្វះទឹក។<br>- ទំនប់លើ ទំនប់ក្រោម ទំនប់ធិបតី (នៅស្រុកអូររាំង) ដែលអនុវត្តដោយមន្ទីរធនធានទឹក ដើម្បីបម្រើវិស័ យទេសចរណ៍ កសិកម្ម និងឧស្សាហកម្ម។ | - យើងត្រូវគិតថាយើងត្រូវសហការគ្នា តាមឋានានុក្រម។<br>- ស្នើសុំឱ្យក្រសួង/មន្ទីរធនធានទឹក សហការ និងយល់អំពីវិស័យទឹក ស្អាតថា ក្រសួង/មន្ទីរ ឧ.វ.ប.ន. ផលិតទឹកស្អាត និងបម្រើសេវាកម្ម សាធារណៈរបស់រដ្ឋ។ |
| **មន្ទីររ៉ែ និង ថាមពល (ត្បូងឃ្មុំ)** | - បើសិន លិខិតអនុញ្ញាតិដោយស្រុក អាចជីកបានជម្រៅ ៣ម៉ែត្រ និងទំហំកន្លះហិចតា បើដល់ខេត្តគឺ ជម្រៅ៥ ម៉ែត្រ និងទំហំ១ហិចតា បើលើសពីនេះត្រូវសុំដល់ក្រសួង<br>- បើករណីយកអាចមន៍ដីទៅចាក់នៅទីតាំងសាធារណៈ សម្រាប់ជួយសង្គម ត្រូវមានលិខិតស្នើសុំ និងការអនុម័ត យល់ព្រម។<br>- មន្ទីរតែងតែសម្របសម្រួលដល់ការងារជីកស្រះសម្រាប់ ផលប្រយោជន៍រួម។ | |
| **ក្រសួង ឧ.វ.ប.ន.** | - ក្រសួងបានណែនាំមន្ទីរឧ.វ.ប.ន។ និងប្រតិបត្តិករ ដើម្បី ធ្វើផែនការតម្រូវការទឹក ដើម្បីងាយស្រួលក្នុងការស្វែង រកប្រភពទឹកផ្គត់ផ្គង់។ | - សូមសហការណ៍គ្នា ជាមួយអាជ្ញាធរ និងមន្ទីរពាក់ព័ន្ធ |

| | | |
|---|---|---|
| **សំណួរ ចម្លើយ** | ***សំណួរ៖*** ក្រសួងជាអ្នកអនុញ្ញាត និងវាយតម្លៃលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពរបស់ប្រតិបត្តិករ តែក្រោយផ្តល់អាជ្ញាបណ្ណ ប្រតិបត្តិករតែងខ្វះប្រភពទឹក ហេតុអ្វី?<br>***ចម្លើយ៖*** គឺគាត់បានសន្យាថានឹងទិញដីបន្ថែមដើម្បីបង្កើតប្រភពទឹក។<br><br>***សំណួរ៖ ទៅកាន់ខេត្តមណ្ឌលគិរី៖*** តើអាចលើកជាទំនប់ ១.៥ ទៅ២ ម៉ែត្របានទេ ?<br>***ចម្លើយ៖*** មន្ទីរឧ.វ.ប.ន. អាចធ្វើបាន ដោយមិនចាំមន្ទីរពាក់ព័ន្ធផ្សេងទៀតទេ។ យើងចុះសិក្សា និងសុំគោលការណ៍ពីថ្នាក់ដឹកនាំខេត្ត ហើយបើមានការចូលរួមពីប្រតិបត្តិករទៀតគឺល្អតែម្តង។ | - សមាគមស្នើសុំក្រសួង ឧ.វ.ប.ន. បង្កើតជាទម្រង់រួមមួយសម្រាប់ប្រតិបត្តិករ ដែលងាយស្រួលក្នុងការបំពេញផែនការតម្រូវការទឹក។ គួរមានការតម្រង់ទិសអំពីទម្រង់នេះ ឬទម្រង់ផ្សេងៗទៀតសម្រាប់ប្រតិបត្តិករ។ សមាគមនឹងជួយសម្របសម្រួលជាមួយប្រតិបត្តិករ នៅពេលដែលមានទម្រង់ទាំងនេះ។ |

## ៣.៦. កម្មវិធីបិទកិច្ចប្រជុំថ្នាក់តំបន់

### ក. របាយការណ៍សកម្មភាព និងលទ្ធផលនៃកិច្ចប្រជុំ

**លោក ផង់ ចិន្តា** ប្រធានផ្នែកទំនាក់ទំនងសមាជិក និងដៃគូ បានធ្វើការបូកសរុបលទ្ធផលនៃកិច្ចប្រជុំរយៈពេលមួយថ្ងៃ ដែលសម្រេចបានប្រកបដោយផ្លែផ្កាដូចការរំពឹងទុក។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ១៥៧នាក់(ស្រី ២៧នាក់) ដែលអញ្ជើញមកពី៖ ១).ក្រសួង ឧ.វ.ប.ន. ២).រដ្ឋបាលខេត្តទាំង៥ (ខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ ព្រៃវែង និងខេត្តស្វាយរៀង) ៣).មន្ទីរពាក់ព័ន្ធទាំង ៧ខេត្ត(មន្ទីរ ឧ.វ.ប.ន. មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីររ៉ែ និងថាមពល មន្ទីរធនធានទឹក និងឧតុនិយម និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី) ៤).ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម ៥).ប្រតិបត្តិករអញ្ជើញមកពីខេត្តទាំង ៧ខាងលើ និង៦).អ្នកឧបត្ថម្ភកម្មវិធីរួមមាន៖ ១.អង្គការ Water.org ២.ក្រុមហ៊ុន KUBOTA ៣.ធនាគារ SME ៤.ធនាគារ FTB ៥.គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចម្រើន ម.ក ៦.ក្រុមហ៊ុន Water Partner (Cambodia) Co.; Ltd ៧.ក្រុមហ៊ុន KCRI International Cooperation Co.; Ltd ៨.ក្រុមហ៊ុន Khmer Angkor Plastic ៩.ក្រុមហ៊ុន E-Power CCL Co.; Ltd ១០.ក្រុមហ៊ុន TCU ១១.ក្រុមហ៊ុន Techzone Plus ១២.ក្រុមហ៊ុន Phnom Penh Plastic Product ១៣.ក្រុមហ៊ុន Khmer Water Supply Holding Co., Ltd. ១៤.ក្រុមហ៊ុន X- Water និង១៥. ក្រុមហ៊ុន LESSO។

ក្នុងនោះ **លោក ចិន្តា** បានលើកឡើងដោយសង្ខេបពីចំណាប់អារម្មណ៍របស់គណៈអធិបតីក្នុងកម្មពិធីបើកកិច្ចប្រជុំ កិច្ចពិភាក្សាតុមូលទាំង២ ដែលសម្របសម្រួលដោយ លោក **លឹម មិញ** និងវាគ្មិនកិត្តិយសអញ្ជើញមកពីមន្ទីរពាក់ព័ន្ធក្នុងវិស័យទឹកស្អាតទាំងអស់។

### ខ. សុន្ទរកថាបិទកិច្ចប្រជុំថ្នាក់តំបន់

**ឯកឧត្តម អ៊ុំ សុថា** បានថ្លែងអំណរគុណចំពោះរដ្ឋបាលខេត្តកំពង់ចាម និងរដ្ឋបាលខេត្តទាំងអស់ មន្ទីរពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ប្រតិបត្តិករ ក្រុមហ៊ុនឧបត្ថម្ភកម្មវិធី និងសមាគមរៀបចំកិច្ចប្រជុំនេះឡើង។ **ឯកឧត្តម** បានផ្តាំផ្ញើថា សូមកុំគិតថា ការងារទឹកស្អាតនេះជាបន្ទុកទទួលខុសត្រូវតែតួអង្គប្រតិបត្តិករមួយ ឬជាបញ្ហាដោយឡែក ប៉ុន្តែត្រូវគិតថា យើងរួមគ្នាទាំងក្រសួង ទាំងថ្នាក់ក្រោមជាតិ ទាំងដៃគូពាក់ព័ន្ធ និងផ្នែកឯកជន ដើម្បីធ្វើការជាមួយគ្នា។ បញ្ហាកង្វះប្រភពទឹកមិនមែនជាបញ្ហារបស់ស្ថាប័នមួយជាច់ដោយឡែកនោះទេ តែវាជាបញ្ហារួម ដែលតម្រូវឱ្យមានការសហការគ្នាក្នុងការ

ទប់ស្កាត់ និងដោះស្រាយ។ យើងដោះស្រាយបញ្ហាគឺត្រូវដោះជាជំហានៗ យើងមិនអាចដោះស្រាយម្ដងបានទាំងអស់នោះទេ។ សូមរៀបចំឱ្យមានផែនការតម្រូវការទឹកភ្ជាប់ជាមួយជាមួយផែនការវិនិយោគ ដើម្បីយើងមានមូលដ្ឋានសុំអន្តរាគមន៍ទៅក្រសួងធនធានទឹក និងឧតុនិយម។ បើសិនជាមានតម្រូវការត្រូវស្តារ ឬជីកស្រះ ឬអាងស្តុកទឹកបម្រើឱ្យការផ្គត់ផ្គង់ទឹកស្អាត ហើយមានបំណងស្នើសុំអន្តរាគមន៍ទៅក្រសួងរ៉ែ និងថាមពល ដើម្បីរួចសួយសារ ក្រសួងនិងជួយពិនិត្យរឿងនេះ ប៉ុន្តែសូមឱ្យស្មោះត្រង់ហើយពិតប្រាកដ។ មុននឹងបញ្ចប់ **ឯកឧត្តម** បានឯកភាពចំពោះអនុសាសន៍នានាដែលបានលើកឡើងក្នុងអង្គប្រជុំ និងត្រូវដាក់បញ្ចូលក្នុងឯកសារជំនួយស្មារតីសម្រាប់ការកំណត់ជាវិធានការដែលត្រូវដោះស្រាយបន្តឱ្យកាន់តែមានប្រសិទ្ធភាព។ ក្នុងនេះចំណុចសំខាន់មួយដែលត្រូវខិតខំធ្វើឱ្យបានគឺការធ្វើវេទិកាពិគ្រោះយោបល់រវាងក្រុមប្រឹក្សាឃុំ/សង្កាត់ ជាមួយប្រជាពលរដ្ឋ និងប្រតិបត្តិករទឹកស្អាត ដើម្បីស្តាប់សំឡេង និងក្តាប់បានបញ្ហាទាំងសង្ខាង គឺអ្នកផ្តល់សេវាទឹកស្អាត និងអ្នកទទួលសេវាទឹកស្អាត(ប្រជាពលរដ្ឋ) ហើយរួមគ្នាដោះស្រាយឱ្យបានទាន់ពេលវេលា។ ជាចុងក្រោយ **ឯកឧត្តម** បានជូនពរដល់គណៈអធិបតី តំណាងមន្ទីរ ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ប្រតិបត្តិករ អ្នកឧបត្ថម្ភគាំទ្រកម្មវិធី និងបុគ្គលិកសមាគម សូមជួបតែសិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ និងសូមវិលត្រឡប់វិញជាមួយនឹងសេចក្តីសុខសុវត្ថិភាព និងសុខភាពល្អ រួមទាំងខ្លួនឯង និងក្រុមគ្រួសារទាំងមូលផងដែរ និងអរគុណដល់អង្គការ Water.org ដែលតែងតែយកចិត្តទុកដាក់គាំទ្រដល់ការអភិវឌ្ឍទឹកស្អាតនៅកម្ពុជា។

កិច្ចប្រជុំថ្នាក់តំបន់ត្រូវបានបញ្ចប់ដោយជោគជ័យនៅវេលាម៉ោង ៥:២៥ល្ងាច នៅក្នុងថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ ស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់៕

ថ្ងៃសុក្រ ១២រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

ធ្វើនៅកំពង់ចាម ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៥

**អ្នកធ្វើកំណត់ហេតុ**

**ផង់ ចិន្តា**

ប្រធានផ្នែកទំនាក់ទំនងសមាជិក និងដៃគូ

នាយកប្រតិបត្តិ

**លឹម មិញ**